# ទស្សនៈ ខេមរយានកម្មសិក្សា

ក្នុងសម័យសង្គមរាស្ត្រនិយម ក្រោមព្រះកិច្ចដឹកនាំដ៏ឈ្លាសវៃនៃសម្តេចព្រះប្រមុខរដ្ឋ ប្រទេសខ្មែរមានភ័ព្វសំណាងខ្ពស់ខ្ពស់បានទទួលឯករាជ្យវប្បធម៌រឹងរឹតតែច្បាស់លាស់ថែមទៀត ពិសេសក្នុងវិស័យសិក្សាធិការជាតិចាប់តាំងពីកំណើតខេមរយានកម្មសិក្សាមក។ ជំហរវប្បធម៌ជាតិ ពឹងផ្អែកមួយផ្នែកធំទៅលើអក្សរនិងភាសាខ្មែរ ក៏ដូចជាពឹងផ្អែកទៅលើខេមរយានកម្មនេះដែរ ដោយសារតែខេមរយានកម្មនេះ ត្រូវចាត់ទុកដូចជាយានផ្ទុកយកចំណេះបរទេស មកលាតត្រដាងផ្សព្វផ្សាយជាភាសាខ្មែរឲ្យជ្រាបដល់ជម្រៅមជ្ឈដ្ឋានមិនត្រឹមតែសិស្សានុសិស្ស គ្រូបាធ្យាយប៉ុណ្ណោះទេ ថែមទាំងដល់ប្រជាពលរដ្ឋគ្រប់ប្រភេទ គ្រប់វ័យថែមទៀតផង។ តាមជំនឿជ្រះថ្លាពេញលក្ខណៈ លើតម្លៃនិងមធ្យោបាយភាសាជាតិ ខេមរយានកម្មសិក្សាប្រាកដជាអាចបម្រើការរៀននិងការបង្រៀនគ្រប់ភូមិសិក្សាទាំងទាបទាំងខ្ពស់ បានទាំងអស់។

ភាសាជាតិណាក៏ដូចជាភាសាជាតិណាដែរ តែងតែមានសភាពលក្ខណៈងាយស្រួលនិងលក្ខណៈលំបាក កប់នៅលាយឡំជាមួយគ្នាជាធម្មតា។ ទុកជាមានសភាពលក្ខណៈដូច្នេះក៏ដោយ ភាសានីមួយៗ តែងតែមានក្បួនច្បាប់របស់ខ្លួនទៅតាមសម័យកាល។ ការខិតខំតម្រឹមតម្រង់គន្លងភាសាឲ្យបានត្រឹមត្រូវ មានឯកភាពនៅក្នុងរង្វង់ក្បួនច្បាប់សុទ្ធ សមតាមបែបបទវិទ្យាសាស្ត្រពេញទី ចាត់ទុកជាការពិបាកមួយដែលអាចបណ្តាលមកអំពីការវិវត្តន៍នៃសង្គមមនុស្ស តម្រូវមនុស្សឲ្យដើរលឿនមុខក្បួនច្បាប់ ឬដើរងាកចេញពីក្បួនច្បាប់ ដើម្បីប្រយោជន៍សេដ្ឋកិច្ចជាតិនិងឯកភាពជាតិ ឬក៏មកអំពីការមិនចុះសម្រុងគ្នារវាងបែបចាស់និងបែបថ្មី ឬមួយមកអំពីដំណើរច្របល់នៃវប្បធម៌ដែលមិនច្បាស់លាស់ថាជារបស់ខ្លួនឬរបស់គេ។ ភាសាខ្មែរសម័យខេមរយានកម្ម បានប៉ះទង្គិចនឹងឧបសគ្គបែបនេះខ្លះដែរ តែការប៉ះទង្គិចនេះ

បានរលាយខ្សុលទៅវិញ ដោយសារតែ **ខេមរយានកម្មជាអង្គការជាតិនិយម** ផ្ដល់អាទិភាពធំទូលំទូលាយក្នុងការបកប្រែពាក្យបច្ចេកទេសបរទេស ជាពាក្យពេចន៍ខ្មែរសុទ្ធៗ មុខនឹងបែរទៅរកពាក្យបាលីសំស្ក្រឹត បារាំង អង់គ្លេស ពីព្រោះតែយល់ថា ត្រូវញ៉ាំងវិវត្តន៍ភាសាខ្មែរឲ្យស្របទៅតាមគោលច្បាប់ខ្មែរបុរាណ។

ដោយការក្ដាប់យកគំនិតនេះជាគោល ខេមរយានកម្មសិក្សា *គ្មានផលប្រយោជន៍អ្វីទៅបង្កើតការពិបាកថ្មីទៅលើការពិបាកចាស់នោះឡើយ* ។ មិនយូរមិនឆាប់ខេមរយានកម្មនឹងប្រែក្លាយទៅជាភ្នាក់ងារចម្បងមួយ ក្នុងការដោលភាសាជាតិឲ្យលឿនទៅមុខ ទាន់ការចាំបាច់នៃសង្គមខ្មែរ សម័យសង្គមរាស្ត្រនិយមពុទ្ធសាសនា សម័យសម្ដេចព្រះសីហនុ។

អាត្មាមានជំនឿស៊ប់លើអង្គការខេមរយានកម្មនេះហើយ ពេញអធ្យាស្រ័យចូលរួមសហប្រតិបត្តិការជាមួយ ដោយគ្មានគិតដល់ការបង់ខាតពេលវេលា និងនឿយកាយពលសោះឡើយ។

ភ្នំពេញ, ថ្ងៃទី៩ កញ្ញា ១៩៦៨

សម្ដេចព្រះសង្ឃរាជគណៈមហានិកាយ **ជួន – ណាត** ជោតញ្ញាណោ